របាយការណ៍ប្រចាំឆមាសទី ១ ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ

## I.ស្ថានភាពមន្ទីរ

### ១-ការងាររដ្ឋបាល បុគ្គលិក

មន្ត្រីរាជការ ចំនួន ៥២ រូប ស្ត្រីចំនួន ០៤ រូប ក្នុងនោះមាន÷

-ប្រធានមន្ទីរ ០១ រូប និង អនុប្រធានមន្ទីរ ០២ រូប

-មន្ត្រីការិយាល័យចំណុះមន្ទីរសរុប÷ ៣២ រូប ស្រី ៤ រូបក្នុងនោះ មន្ត្រីកម្មសិក្សាថ្មីចំនួន ២ រូប ស្រី ០ រូប និង បុគ្គលិកបណ្តែតចំនួន ២ រូប ស្រី ០១ រូប

-មន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ក្រុង សរុប÷ ១៧ រូប ស្រី ០ រូប

ការងារលិខិតស្នាមមាន÷

-បានទទួលលិខិតចូលតាមបណ្តាក្រសួង អង្គភាពនានា ចំនួន ២១៧ លិខិត

-បានទទួលលិខិតចូលពីក្រសួងសាមុី ចំនួន ៣២ លិខិត

-លិខិតចេញទៅតាមបណ្តាអង្គភាព ស្ថាប័ននានា និងអង្គភាពក្រោមឱវាទចំនួន ២៣៧លិខិត

-បានធ្វើសំណើសុំពិនិត្យលើរបាយការណ៏ផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារ មន្ត្រីរាជការ ប្រចាំ រៀងរាល់ខែ ឆ្នាំ ២០១៥ ដែលមាន ក្នុងតារាង បៀវត្ស (មិនមានការប្រែប្រួល)

-បានបញ្ជូនឈ្មោះបុគ្គលិកអណ្តែត និងលេខគណនេយ្យ សម្រាប់បើកផ្តល់បៀវត្ស និង បានបញ្ជូនកូន១នាក់របស់មន្ត្រីជូនទៅ មន្ទីរមុខងារសាធារណៈខេត្តកំពង់ធំ

-បានធ្វើរបាយការណ៍វឌ្ឍនភាពសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការ តាមប្រព័ន្ធធនាគារ រៀងរាល់ខែ ឆ្នាំ ២០១៥ ដែលមានក្នុងតារាងបៀវត្សមានដូចខាងក្រោម ÷

| ស្ថាប័ន/ អង្គភាព | ចំនួនមន្ត្រីក្នុងតារាងបៀវត្ស | ចំនួនមន្ត្រីមានគណនីធនាគារ | ចំនួនមន្ត្រីមានបើកបៀវត្សតាមធនាគារ | ចំនួនមន្ត្រីគ្មានគណនីធនាគារ | ចំនួនមន្ត្រីជាក់ស្តែង |
|---|---|---|---|---|---|
| មន្ទីរអភិវឌ្ឍន៍ ជនបទ ខេត្ត កំពង់ធំ | ៥៤ | កាណាឌីយ៉ា=២៧ន<br>អេស៊ីលីដា= ២៧ ន | ៥៤ | ០០ | ៥២ |

### ២-ការងារគណនេយ្យ និងហិរញ្ញវត្ថុ

| ជំពូក | បរិយាយ | ស្ថានភាពឥណ ទាន គិតជារៀល | បណ្តាខែមុន | ចំណាយក្នុងខែ 06 | ចំណាយ បូក យោង | សមតុល្យ |
|---|---|---|---|---|---|---|
| ៦០ | ការទិញ | 154,700,000 | 3,444,050 | 1,675,000 | 5,119,050 | 149,580,950 |
| ៦១ | សេវាខាងក្រៅ | 426,600,000 | 31,191,350 | 23,106,000 | 54,297,350 | 372,302,650 |
| ៦៣ | ពន្ធ និងអាករ | 3,000,000 | 0 | 0 | 0 | 3,000,000 |
| ៦៤ | បន្ទុកបុគ្គលិក | 412,600,000 | 166,196,890 | 36,400,520 | 202,597,410 | 210,002,590 |
| សរុបរួម | | 996,900,000 | 200,832,290 | 61,181,520 | 262,013,810 | 734,886,190 |

**៣-ការងារផែនការ និង ស្ថិតិ**

-បានចុះតាមដាន សហការលើការងារអនុវត្ត គម្រោងរបស់ អង្គការ IDE ក្នុងនោះពិនិត្យឃើញថា ÷នៅស្រុក ប្រាសាទ-សំបូរ មានទីកន្លែងលក់បង្គន់ចំនួន ១ កន្លែង ប្រាសាទបល្ល័ង្គ មានទីកន្លែងលក់បង្គន់ចំនួន ២ កន្លែង និង ស្រុក ស្ទោង មានទីកន្លែងលក់បង្គន់ចំនួន ៤ កន្លែង

-បូកសរុបរបាយការណ៍វឌ្ឍនភាពប្រចាំខែ មករា កុម្ភៈ មីនា មេសា ឧសភា មិថុនា ត្រីមាសទី ១ និង ឆមាសទី១ ឆ្នាំ ២០១៥

-បានរៀបចំផែនការយុទ្ធសាស្ត្រ ២០១៦-២០១៨ ជូននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត កំពង់ធំ

**៤-ការងារអធិការកិច្ច និងសវនកម្ម**

- នៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៥ គណៈប្រតិភូអធិការកិច្ចនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល-ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៥
- បានអមដំណើរគណៈកម្មការអន្តរក្រសួង ដឹកនាំដោយ ឯកឧត្តម **សាន វិសាល** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ចុះពិនិត្យ និងវាយតម្លៃ បញ្ចប់សុពលភាពថែទាំខួប ០១ខ្សែ ប្រវែង ៨,៨៧ គ.ម នៅឃុំទីពោ ស្រុកសន្ទុក និងពិនិត្យផ្លូវ ០១ ខ្សែ ផ្លូវពីក្រវ៉ា- វាលស្ព័រ ផ្លូវដែលត្រូវលើកគម្រោងថែទាំខួបឆ្នាំ ២០១៥
- នៅថ្ងៃទី ២០-២២ ខែមេសា ឆ្នាំ ២០១៥ ប្រតិភូអាជ្ញាធរសវនកម្មជាតិ បានចុះធ្វើសវនកម្មលើការគ្រប់គ្រងចំណាយការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការអនុលោមតាមបទប្បញ្ញត្តិ និងប្រព័ន្ធគ្រប់គ្រង សម្រាប់ការិយបរិច្ឆេទ ឆ្នាំ ២០១៤ និងបណ្តាឆ្នាំពាក់ព័ន្ធ

**៥-ការងារទំនាក់ទំនងសាធារណៈ និងកិច្ចប្រជុំផ្សេងៗ**

- លោក មុំ ថែម ប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមនៅថ្នាក់ខេត្តបានចំនួន ៤៥ លើក
- លោក តាន់ វាសនា អនុប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមថ្នាក់ខេត្តបាន ២៥ លើក
- លោក សេង ជាសុខ អនុប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមថ្នាក់ខេត្តបាន ៤៩ លើក

- មន្ទីរបានសហការជាមួយរដ្ឋបាលខេត្តកំពង់ធំ រៀបចំពិធីផ្សព្វផ្សាយលទ្ធផលសន្និបាតបូកសរុបការងារឆ្នាំ ២០១៤ និង ទិសដៅការងារឆ្នាំ ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នាថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ នៅសាលប្រជុំអគារ B សាលាខេត្ត កំពង់ធំក្រោមអធិបតីភាព **ឯកឧត្តម ហួត សារឹម** អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទឯកឧត្តម **ដៀប ពីរី** សមាជិកក្រុមប្រឹក្សាខេត្ត **ឯកឧត្តម គង់ វិមាន** អភិបាលរង ខេត្ត សមាជិក សមាជិកាមកពីមន្ទីរអង្គភាពជុំវិញខេត្ត កងកំលាំងប្រដាប់អាវុធទាំងបីប្រភេទ ក្រុមប្រឹក្សា គណៈអភិបាលស្រុក ក្រុង អង្គការជាតិ អន្តរជាតិក្នុងខេត្ត មន្ត្រីរាជការមន្ទីរអ .ជ.ប លោក លោកស្រី ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលអ្នកចូលរួមសរុប ១៣៥ នាក់ ស្រី ១០ នាក់។
- លោក **សេង ជាសុខ** អនុប្រធានមន្ទីរបានចូលរួមប្រជុំប្រចាំឆ្នាំ ២០១៤-២០១៥ជាមួយអង្គការក្រៅរដ្ឋាភិបាលដៃគូរ នៅសាលប្រជុំក្រសួង អ ជ ប នាថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ ក្រោមអធិបតីភាព **ឯកឧត្តម ហាប់ អូម៉ាលី** អនុរដ្ឋលេខាធិការនិង ជាប្រធានក្រុមការងារ
- មន្ទីរបានរៀបចំពិធីសូត្រមុន និង ពិសាភោជនីអាហារសាមគ្គីនៅថ្ងៃទី០៩ខែ មេសា ឆ្នាំ ២០១៥ ដែលមាន អ្នកចូលរួមមន្ត្រីក្នុងមន្ទីរ អជ ប ទាំងអស់ ព្រមទាំងក្រុមប្រឹក្សា គណៈអភិបាល អង្គភាពមន្ទីរជុំវិញខេត្ត
- មន្ទីរបានរៀបចំការប្រជុំមួយ ស្តីពីការរៀបចំផែនការសកម្មភាពថ្នាក់ជាតិ សម្រាប់ការងារផ្តល់សេវាទឹកស្អាត និង ការលើកកម្ពស់អនាម័យជនបទឆ្នាំ ២០១៤ - ២០១៨ សមាសភាពចូលរួម តំណាងអង្គការជាតិ និង អន្តរជាតិក្នុងខេត្ត ចំនួន ៩ និង ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យជំនាញ
- មន្ទីរបានរៀបចំប្រជុំប្រចាំខែ ស្តីពីការងារបូកសរុបរបាយការណ៍ប្រចាំរៀងរាល់ខែក្រោមអធិបតីភាពលោក ប្រធានមន្ទីរ ដោយមានការចូលរួមរបស់លោកអនុប្រធានមន្ទីរទាំងពីរ និងប្រធាន អនុប្រធានការិយាល័យ ទាំងអស់ក្នុងមន្ទីរ

II. **សកម្មភាពតាមវិស័យ**

**១-ការងារផ្លូវជនបទ**( ថវិកាកម្មវិធី)

- លោក **សេង ជាសុខ** អនុប្រធានមន្ទីរ និងលោក **ម៉ាក់ មុន្នា** ប្រធានការិយាល័យផ្លូវលំ នៅ ថ្ងៃទី ០៨ ខែមករា ២០១៥ បានចូលរួមជាមួយគណៈកម្មាធិការចម្រុះដឹកនាំដោយ **ឯកឧត្តម ហួន វ៉ាន់និត** អភិបាលរងខេត្ត ចុះត្រួតពិនិត្យក្រុមហ៊ុនចំការកៅស៊ូ CRCK ឈូសឆាយប៉ះពាល់ដីសហគមន៍ក្នុងឃុំដងកាំបិទ ស្រុក សណ្តាន់
- ចុះស្រង់ទិន្នន័យផ្លូវជនបទបានចំនួន ៣០ ខ្សែ ប្រវែង ៨,៧ គ.ម និង បានធ្វើបច្ចុប្បន្នភាពផ្លូវចំនួន ៥ ខ្សែ ប្រវែង ២៩,០២ គ.ម ក្នុងនោះ÷ ផ្លូវក្រាលកៅស៊ូ ៣ខ្សែ ប្រវែង ១១,៥ គ.ម និង ផ្លូវក្រាលក្រួសក្រហម ចំនួន ២ ខ្សែ ប្រវែង ១៧,៥២០ គ.ម និង -ចុះស្រង់ទិន្នន័យផ្លូវជនបទប្រភេទ ៤ ដែលនៅសេសសល់ និងធ្វើបច្ចុប្បន្នភាពខ្សែផ្លូវស្ថិតក្នុងស្រុកស្ទឹងសែន កំពង់ស្វាយ មាន÷

ក. ទិន្នន័យផ្លូវជនបទ ប្រភេទ ៤ បាន ១២ ខ្សែ ប្រវែងសរុប ១២,៥០ គ.ម ក្នុងស្រុក កំពង់ស្វាយ

ខ. ធ្វើបច្ចុប្បន្នភាពខ្សែផ្លូវ បានចំនួន ២ ខ្សែ ប្រវែងសរុប ១៦,៧០ គ.ម ស្ថិតនៅក្រុង ស្ទឹងសែន និងស្រុក កំពង់ស្វាយមាន÷

- ផ្លូវកំពង់ក្របៅ-កំពង់ស្វាយ ប្រវែង ១២,២ ម (ផ្លូវ DBST ៣,៥គម របស់មន្ទីរសាធារណៈការ និង ដឹកជញ្ជូនខេត្ត)
- ផ្លូវកំពង់រទេះ÷ កំពង់គោប្រវែង ១៤,៥ ម (ផ្លូវ DBST ៤ គ.ម របស់មន្ទីរសាធារណៈការនិង ដឹកជញ្ជូនខេត្ត)
- ត្រៀមរៀបចំអនុវត្តគម្រោងផ្លូវសង្គ្រោះបន្ទាន់ ពីជ័យជិនះ- ស្វាយកាល់ ប្រវែង ៣,២ គ.ម នៅឃុំកកោះ ស្រុកសន្ទុក
- រៀបចំសំណើគម្រោង ជួសជុលប្រចាំ និងខួប ផ្លូវជនបទ ឆ្នាំ ២០១៦ ក្នុងនោះ÷

ក-ផ្លូវថែទាំប្រចាំ ១៩ ខ្សែ ប្រវែងសរុប ១៤៤,៣៧ គ.ម

ខ-ផ្លូវថែទាំខួប ២៤ ខ្សែ ប្រវែងសរុប ១៤៩,៣៧ គ.ម

គ-បានចុះពិនិត្យទីតាំងផ្លូវ ០១ ខ្សែ ពីភូមិអញ្ចាញ- កងមាស ប្រវែង ១,៧ គ.ម ក្នុងឃុំត្នោតជុំ ស្រុកបារាយណ៍ ដែលត្រូវបានស្នើសុំពីសមាជិកក្រុមប្រឹក្សាឃុំនោះ

ឃ-ដាក់លិខិតជូន ឯកឧត្តម អភិបាលខេត្តកំពង់ធំ ដើម្បីជួយជម្រុញសហគមន៍ចូលរួមដាំដើមឈើតាមដងផ្លូវ ដែលមន្ទីរអភិវឌ្ឍន៍ជនបទបាននឹងកំពង់អនុវត្ត ឆ្នាំ ២០១៥

ង-ការិយាល័យផ្លូវលំជនបទ បានដាក់ស្នើសុំ GPS មួយគ្រឿងទៅក្រុមការងារទិន្នន័យផ្លូវជនបទថ្នាក់ក្រសួងអភិវឌ្ឍន៍ជនបទ

ច-បានរៀបចំតារាងឈ្មោះផ្លូវ និងសំណង់សិល្បៈការ ដែលមន្ទីរបាន និងកំពង់អនុវត្ត ឆ្នាំ ២០១៥ ជូននាយកដ្ឋានផ្លូវលំជនបទដើម្បីរៀបចំធ្វើផែនទី

- នាយកដ្ឋានផ្លូវលំជនបទ និងតំណាងក្រសួងហិរវត្ថុ ចុះពិនិត្យផ្លូវ០២ខ្សែ ប្រវែង ១៤,១គម សម្រាប់ធ្វើការថែទាំខួបក្នុងឆ្នាំ ២០១៥ ស្ថិតនៅ ឃុំ កំពង់ស្វាយ និងឃុំ ត្រពាំងឫស្សី ស្រុកកំពង់ស្វាយ
- បានចូលរួមជាមួយសហគមន៍, អាជ្ញាធរស្រុកប្រាសាទសម្បូរ និងតំណាងក្រុមហ៊ុន Royal Mekong ចុះពិនិត្យ បង្ហាញទីតាំងផ្លូវថ្មីវាងបរិវេណប្រាសាទសម្បូរ ដែលមានប្រវែង ១៤,៩ គ.ម
- បានសិក្សា ប៉ាន់ស្មានតម្លៃសំរាប់គម្រោងជួសជុលផ្លូវបន្ទាន់ ដែលខូចខាតដោយទឹកជំនន់ ចំនួន ០១ ខ្សែ ប្រវែង ៣,២០គម នៅឃុំ កកោះ ស្រុកសន្ទុក
- ជូនក្រុមហ៊ុន ហេង សម្បត្តិ ពិនិត្យទីតាំងផ្លូវសម្រាប់គម្រោងរបស់ក្រសួងអភិវឌ្ឍន៍ជនបទជួសជុលផ្លូវបន្ទាន់ឆ្នាំ ២០១៥ ដែលខូចខាតដោយទឹកជំនន់ ចំនួន ០១ ខ្សែ លាបទង -ម្យាក្រង ប្រវែង ៦,៣ គ.ម នៅឃុំ កំពង់ចិនត្បូង និងឃុំម្យាក្រង ស្រុកស្ទោង

**២-ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ** (ចរិកាកម្មវិធី)

- បានចុះជួបអាជ្ញាធរភូមិ ឃុំ ក្នុងការបំពេញទំរង់លំអិត លើទិន្នន័យអណ្តូងនៅឃុំ សូយោង ស្រុកបារាយណ៍
- បានចុះជ្រើសរើសទីតាំងអណ្តូងចំនួន ៤១ សម្រាប់ជួសជុល ថែទាំនៅស្រុកសន្ទុក

**៣-ការងារសុខភាពអនាម័យជនបទ**

- ចុះប្រមូលទិន្នន័យអ្នកជំងឺអេដ្ឋដែលចូលសម្រាកក្នុងមន្ទីរពេទ្យខេត្ត និងនៅសហគមន៍ ២ ថ្ងៃ

- ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៥ ចូលរួមប្រជុំក្រុមការងារបច្ចេកទេសសុខាភិបាលខេត្តកំពង់ធំ ស្តីពីប្រធានបទនៃការបង្ហាញរបស់អង្គការ GIZ ពីការងារផែនការសកម្មភាពសុខាភិបាលសម្រាប់ឆ្នាំ២០១៥ នៅមន្ទីរសុខាភិបាលខេត្តកំពង់ធំ
- ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៥ បានចូលរួមប្រជុំប្រចាំខែសម្រាប់ការងាររបស់មន្ទីរ ស្តីពីការងាររដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ ២០១៥ ក្រោមអធិបតីភាពលោកប្រធានមន្ទីរ និងជាប្រធានអង្គប្រជុំ
- បានត្រៀមរៀបចំឯកសារធ្វើបទបង្ហាញអំពីការវិភាគស្ថានភាពទឹក និងអនាម័យ ឆ្នាំ ២០១៤ សម្រាប់សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការកសាងផែនការសកម្មភាពជាតិ សម្រាប់ថ្នាក់ខេត្ត ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទសម្រាប់ឆ្នាំ ២០១៤-២០១៨ ដែលប្រព្រឹត្តិទៅនៅថ្ងៃទី ២៨-២៩ ខែឧសភា ឆ្នាំ ២០១៥
- បានពិភាក្សាពិគ្រោះយោបល់គ្នា ជាមួយការិយាល័យទឹកស្អាត ក្នុងការបំពេញក្របខ័ណ្ឌលទ្ធផលការងារ និង ការប៉ាន់ប្រមាណតម្លៃសកម្មភាពសូចនាករ (ដោយផ្អែកលើសូចនាករធាតុចេញនៃលទ្ធផលរយៈមធ្យមទី ៣,៤,៥)
- ដោយមានកិច្ចសហការ ឧបត្ថម្ភគាំទ្រពីអង្គការដៃគូរអភិវឌ្ឍន៍ចំនួន ៥ ក្នុងខេត្ត ដែលមានសកម្មភាពទឹកស្អាត និងអនាម័យ គឺមានអង្គការ CWS,CARITAS,Muslim Aid, Toek SaArt 1001 និងអង្គការ COWS មន្ទីរបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ការកសាងផែនការសកម្មភាពជាតិ សម្រាប់ថ្នាក់ខេត្ត ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទឆ្នាំ ២០១៤-២០១៥ អ្នកចូលរួមមកពី មន្ទីរពាក់ព័ន្ធ អង្គការដៃគូរអភិវឌ្ឍន៍នានាក្នុងខេត្ត,លោកអភិបាលស្រុក ក្រុមប្រឹក្សាឃុំ ប្រធានមណ្ឌលសុខភាពស្រុក នាយកសាលាបឋមសិក្សា និងអនុវិទ្យាល័យតាមបណ្តាឃុំ ស្រុកសរុបចំនួន ៦៩ នាក់ ស្រី ០៧ នាក់

**៤-ការងារអភិវឌ្ឍន៍សហគមន៍** (ថវិកាកម្មវិធី)

- បានលើកផែនការបណ្តុះបណ្តាលស្តីពី ការបញ្ជ្រាបការគ្រប់គ្រងគ្រោះមហន្តរាយដាក់ចូលក្នុងផែនការអភិវឌ្ឍន៍ ជូននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ចំនួន៣វគ្គ នៅឃុំ កំពង់ស្វាយ ឃុំ ឈូក និង ក្លែង
- ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៥ ចុះតាមដានពង្រឹងសកម្មភាពរបស់ (គអភ) នៅក្នុងឃុំ តាំងក្រសៅ ស្រុកប្រាសាទសំបូរ រួមមានភូមិចំនួន ១៥ ដែលមានសមាជិក (គអភ) សរុប ១៣៧ នាក់ ស្រី ៥៨ នាក់ ក្នុងនោះមានការប្រែប្រួលចំនួន ០៦ ភូមិ រួមមានសមាជិក ០៩ នាក់ ស្រី ០៦ នាក់ ហើយក្រុមប្រឹក្សាឃុំ ក៏បានធ្វើការផ្លាស់ប្តូរជំនួសឡើងវិញ។

**+ ការវាយតម្លៃ÷**

- ឃុំសាលាវិស័យ មានសមាជិក (គអភ) ចំនួន ៦៩ ភាគរយ ស្មើនឹង ១០៨ នាក់ បានយល់ដឹងពីតួនាទី និងបានបំពេញភារកិច្ចរបស់ខ្លួនម្នាក់ៗ នៅក្នុងសកម្មភាពផ្សេងៗ និងគម្រោងអភិវឌ្ឍន៍នានា នៅក្នុងមូលដ្ឋានរបស់ពួកគាត់ ចំណែក ៣១ ភាគរយ ស្មើនឹង ៤៩ នាក់ ទៀត ពុំបានយល់ដឹងអំពីតួនាទីភារកិច្ចរបស់ខ្លួនឡើយ
- ឃុំទួលគ្រើល មានសមាជិក (គអភ) ចំនួន ៧១ ភាគរយ ស្មើនឹង ៤៣ នាក់ បានយល់ដឹងអំពីតួនាទី និង

បានបំពេញភារកិច្ចរបស់ខ្លួនម្នាក់ៗ នៅក្នុងសកម្មភាព កម្មវិធី គម្រោងអភិវឌ្ឍន៍នានា វគ្គបំពាក់បំប៉នជំនាញផ្សេងៗ នៅក្នុងឃុំរបស់ពួកគាត់ ។ ចំណែក សមាជិក (គអភ) ចំនួន ២៩ ភាគរយ ស្មើនឹង ១៨ នាក់ទៀត មិនបានយល់ដឹងអំពីតួនាទី និងភារកិច្ចរបស់គាត់ឡើយ ពីព្រោះពួកគាត់ជាប់រវល់តែនឹងកិច្ចការរកស៊ីដើម្បីដោះស្រាយបញ្ហាជីវភាពរបស់ក្រុមគ្រួសារពួកគាត់

- ឃុំផាន់ញើម មានសមាជិក (គអភ) ចំនួន ៦៨ ភាគរយ ស្មើនឹង ៤៤ នាក់ បានយល់ដឹងពីតួនាទី និងបានបំពេញភារកិច្ចរបស់ខ្លួនម្នាក់ៗ នៅក្នុងសកម្មភាពផ្សេងៗ និងគម្រោងអភិវឌ្ឍន៍នានា នៅក្នុងមូលដ្ឋានរបស់ពួកគាត់ ចំណែក ៣២ ភាគរយ ស្មើនឹង ២០ នាក់ ទៀត ពុំបានយល់ដឹងអំពីតួនាទីភារកិច្ចរបស់ខ្លួនឡើយ
- ឃុំតាំងក្រសៅ មានសមាជិក(គអភ) ចំនួន ៦៧ ភាគរយ ស្មើនឹង ៩២ នាក់ បានយល់អំពីតួនាទី និងអនុវត្តការបំពេញការងាររួមនៅក្នុងការអភិវឌ្ឍន៍ចម្រុះនៅមូលដ្ឋានរបស់គាត់ ចំណែកចំនួន ៣៣ភាគរយ ស្មើនឹង ៤៥នាក់ ទៀត ពុំបានយល់ដឹងអំពីតួនាទីភារកិច្ចរបស់ (គអភ) នៅឡើយ ពីព្រោះពួកគាត់ពុំសូវមានចំណាប់អារម្មណ៍ចំពោះការងារអភិវឌ្ឍន៍ចម្រុះ សកម្មភាពផ្សេងៗ កម្មវិធី គម្រោងអភិវឌ្ឍន៍នានា នៅក្នុងមូលដ្ឋានរបស់គាត់ឡើយ ព្រោះពួកគាត់បានផ្តោតតែទៅលើបញ្ហាជីវភាពក្រុមគ្រួសារគាត់ប៉ុណ្ណោះ
- ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ចុះទៅឃុំត្បូងក្រពើ ដើម្បីសម្របសម្រួលពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ព្រមទាំងមេភូមិ អនុភូមិ ស្តីពីការជ្រើសរើសយកភូមិចំនួន ០២ ជាពិសេសប្រធាន ឬក្បាលម៉ាស៊ីនដឹកនាំ (គអភ) ដើម្បីត្រៀមឡើងធ្វើបទបង្ហាញក្នុងពេលធ្វើសិក្ខាសាលានាពេលខាងមុខ អំពីការងារអភិវឌ្ឍន៍សហគមន៍ និងដំណើរការប្រព្រឹត្តរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ផ្អែកតាមការសិក្សារបស់ក្រុមប្រឹក្សាឃុំ និងបណ្តាមេភូមិ-អនុភូមិទាំង ០៥ បានឯកភាពអនុម័តយកភូមិចំនួន ០២ គឺភូមិកាលមេឃ និងភូមិចុងដា
- ថ្ងៃទី ១១-១២ ខែ មិថុនា ឆ្នាំ ២០១៥ ចុះទៅឃុំចំណាក្រោម ស្រុកស្ទោង ដើម្បីតាមដានអំពីសកម្មភាព និងការបម្រែបម្រួលទិន្ន័យ (គអភ) ដោយបានប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ និងបណ្តាមេភូមិ-អនុភូមិទាំង ១០ ស្ថិតក្នុងឃុំនេះផ្ទាល់ ជាក់ស្តែងមានការប្រែប្រួលចំនួន ០៣ ភូមិ គឺជីអាប់ សណ្តាន់ និងភូមិព្រះនង្គ័ល មានសមាជិកសរុប ០៨ នាក់ ស្រី ០៣ នាក់ បន្ទាប់មកក្រុមប្រឹក្សាឃុំ និងមេភូមិបានជ្រើសរើសតែងតាំងជំនួសឡើងវិញហើយ

**+ ការវាយតម្លៃ÷**

- ឃុំចំណាក្រោមៈ (គអភ) ទាំង ១០ ភូមិ មានសមាជិកសរុបជាក់ស្តែង ៧៨ នាក់ ស្រី ៣២ នាក់ ក្នុងនោះផងដែរ ចំនួន ៦៥ ភាគរយ ស្មើនឹង ៥១ នាក់ស្រី ១៩ នាក់ បានយល់ដឹងពីតួនាទី និងបានបំពេញភារកិច្ចរបស់ខ្លួនម្នាក់ៗ នៅក្នុងសកម្មភាពផ្សេងៗ និងគម្រោងអភិវឌ្ឍន៍នានា នៅក្នុងមូលដ្ឋានរបស់ពួកគាត់ ចំណែក ៣៥ភាគរយ ស្មើនឹង ២៧ នាក់ ស្រី ១៣ នាក់ ទៀត ពុំបានយល់ដឹងអំពីតួនាទីភារកិច្ចរបស់ខ្លួនទេ ពីព្រោះភូមិរបស់ពួកគាត់ពុំ ដែលបានឆ្លងវគ្គបណ្តុះបណ្តាលម្តងណាឡើយ តាំងតែពីចេញសេចក្តីសម្រេចបង្កើត (គអភ) នោះ

**៥-ការងារបណ្តុះបណ្តាល និង ស្រាវជ្រាវ** (សកម្មភាពអភិវឌ្ឍន៍ធនធានមនុស្សក្នុងប្រទេស)

| ល | ប្រភេទវគ្គ | ឈ្មោះមន្ត្រី | តួនាទី | ខ្លឹមសារ | រយៈពេល | ចំនួន | ទីកន្លែង | អង្គភាព |
|---|---|---|---|---|---|---|---|---|

| .វ | ប | ស | ទ | ស<br>.វ | ចូលរួម | | | | ថ្ងៃ | | រៀបចំ |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | | ស | | | 1-លោក ស៊ីន វុទ្ធា | ប្រធានការិ-<br>ខេត្ត | បូកសរុបលទ្ធផលឆ្នាំ<br>២០១៤ និងលើកកម្ពស់<br>ផែនការឆ្នាំ ២០១៥ | 12-<br>15/01/15 | 04 | បាត់<br>ដំបង | Unicef |
| 2 | ប | | | | 1-លោក ប្រាក់ មុត | ប្រធានការិ-<br>ខេត្ត | CLTS | 13-<br>21/01/15 | 09 | កំពង់ធំ | Plan<br>Internati<br>onal |
| 3 | | ស | | | លោក សេង ជាសុខ | អនុប្រធានមន្ទីរ | ការចាប់ផ្តើមអនុវត្តកម្មវិធីកាត់<br>បន្ថយហានិភ័យនៃគ្រោះ<br>មហន្តរាយថ្នាក់សហគមន៍ | ០៦/០២/<br>១៥ | ០១ | សាលា<br>ខេត្ត<br>កំពង់ធំ | កាកបាទ<br>ក្រហមកម្ពុ<br>ជា |
| 4 | ប | | | | លោក ស៊ីន វុទ្ធា | ប្រធាន<br>ការិយាល័យ | សិក្សាឡើងវិញលើកម្មវិធីស្តីពី<br>ស្រ្តីទទួលបាននិងគ្រប់គ្រង<br>ចាត់ចែងធនធានដីធ្លី | ១០-១១/<br>០២/១៥ | ០២ | ខេត្ត<br>ព្រះ<br>សីហនុ | អង្គការអុក<br>ស្វាម |
| 5 | | ស | | | លោក តាន់ វាសនា | អនុប្រធានមន្ទីរ | សិក្ខាសាលាប្រចាំឆ្នាំ ស្តីពី<br>កម្មវិធីផែនការសុវត្ថិភាព<br>ទឹកផឹកជនបទ | ២៩-០១/<br>០១/១៥ | ១ | ភ្នំពេញ | នាយក<br>ដ្ឋានផ្គត់<br>ផ្គង់ទឹក<br>ជនបទ |
| 6 | | ស | | | លោក ម៉ុំ ចែម<br>1-លោក ចាន់ វុធថា<br>2-លោក សុខ សំអន<br>3- លោក ហ៊ុយ សុធារ៉ា | ប្រធានមន្ទីរ<br>ប្រធាន អនុ<br>ប្រធាន<br>ការិយាល័យ<br>និង បុគ្គលិក | សិក្ខាសាលាពិគ្រោះ<br>យោបល់តម្រង់ទិសថ្នាក់<br>ជាតិស្តីពីក្របខ័ណ្ឌនៃ<br>ផែនការសម្រាប់វិស័យផ្គត់<br>ផ្គង់ទឹកស្អាតនិងអនាម័យ<br>ជនបទ<br>សិក្ខាសាលាផ្សព្វផ្សាយ<br>គោលការណ៍ណែនាំស្តីពីនិ<br>តិវិធីអនុវត្តថវិកាកម្មវិធី<br>ដៅថ្នាក់រាជធានីខេត្ត | ០៤-០៧/<br>០២/១៥<br>១០/០២/<br>២០១៥ | ២<br>១ | ភ្នំពេញ<br>សៀម<br>រាប | នាយក<br>ដ្ឋានផ្គត់<br>ផ្គង់ទឹក<br>ជនបទ<br>ក្រសួង<br>សេដ្ឋកិច្ច<br>ហិ/វ |
| 7 | | ស | | | 1-លោក ម៉ាក់ មុន្នា<br>2-លោក គួង គា<br>3-លោក គៀត វឿន<br>4--លោក ស៊្រុន ហួត | ប្រធាន អនុ<br>ប្រធាន<br>ការិយាល័យ<br>និង បុគ្គលិក | បូកសរុបបញ្ជីសារពើភណ្ឌ<br>និងផែនទីផ្លូវជនបទ | ១០-១២/<br>០២/<br>២០១៥ | ៣ | ភ្នំពេញ | ក្រសួង<br>អភិវឌ្ឍន៍<br>ជនបទ |
| 8 | | ស | | | 1-លោក ម៉ុំ ចែម<br>2-លោក សេង ជាសុខ<br>3-លោក តាន់ វាសនា<br>4-លោក សរ វឌ្ឍនី<br>5-លោក ហេង សុខ<br>6-លោក ចាន់ វុធថា<br>7-លោក ម៉ាក់ មុន្នា<br>8-លោក ប្លង់ សាឡន<br>9-លោក ប្រាក់ មុត<br>10-លោក ថុង ប៊ុនធាង | ប្រធាន អនុ<br>ប្រធានមន្ទីរ<br>ប្រធាន អនុ<br>ប្រធាន<br>ការិយាល័យ<br>និង បុគ្គលិក | សន្និបាតបូកសរុបឆ្នាំ<br>២០១៤ និងលើកទិសដៅ<br>ឆ្នាំ ២០១៥ | ១២/០២/<br>២០១៥ | ១ | ភ្នំពេញ | ក្រសួង<br>អភិវឌ្ឍន៍<br>ជនបទ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | 11-លោក ស្រេង ណូត<br>12-លោក ស៊ីន វុទ្ធា<br>13-លោក ឃុន ពិសាល<br>14-លោក ស្រ៊ុន ហ្វូត | | | | | | |
| 9 | | ស | | | លោក មុំ ចែម | ប្រធានមន្ទីរ | សន្និបាតជាតិអាហារូបត្ថម្ភ | ០៣-០៤/០៣/១៥ | ០២ | ភ្នំពេញ | ក្រុមប្រឹក្សាស្តារវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ |
| 10 | ប | | | | លោក ប្លង់ សាឡុន | ប្រធានការិយាល័យខេត្ត | ពីការប្រមូលទិន្នន័យ សន្តិសុខស្បៀង អាហារូបត្ថម្ភ និងការគ្រប់គ្រងគ្រោះមហន្តរាយ | ០៦/០៣/១៥ | ០១ | ខេត្តកំពង់ធំ | ក្រុមប្រឹក្សាស្តារវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ |
| 11 | | ស | | | លោក ប្លង់ សាឡុន | ប្រធានការិយាល័យខេត្ត | គ្រោះមហន្តរាយដើម្បីពង្រឹងសមត្ថភាពដល់ DCDM និង CCDM | ០៩/០៣/១៥ | ០១ | ខេត្តកំពង់ធំ | PCDM កំពង់ធំ |
| 12 | ប | | | | ១.លោក ចាន់ សង្ហា<br>២.លោក មូល ចាន់នី | អនុប្រធានការិយាល័យខេត្តនិង មន្ត្រីស្រុកបារាយណ៍ | រចនាគម្រូប្លង់បង្គន់ និង ការសាងសង់បង្គន់ | 23-27/03/15 | ០៥ | កំពង់ធំ | CWS |
| 13 | ប | | | | លោក ម៉ាក់ មុន្នា | ប្រធានការិយាល័យខេត្ត | GIS | 06-10/04/15 | ០៥ | ភ្នំពេញ | MRD & គម្រោង RRIP |
| 14 | | ស | | | លោក ប្រាក់ មុត | ប្រធានការិយាល័យខេត្ត | កែសម្រួលឯកសារឧបករណ៍វាយតម្លៃ និងការគូសផែនទីសហគមន៍ (PSAM) | 07-10/04/15 | ០៤ | កំពង់ចាម | អង្គការ PLan |
| 15 | ប | | | | ១.លោក ប្លង់ សាឡុន<br>២.លោក អុល ពេជ្រចរិយា | ប្រធានការិ-ខេត្ត និង មន្ត្រីការិ-រដ្ឋបាល | ប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃ ដោយប្រើប្រាស់ Computerized System | 23/04/15 | ០១ | កំពង់ចាម | MRD/ADB |
| 16 | | ស | | | លោក ប្លង់ សាឡុន | ប្រធានការិ-ខេត្ត | ស្តីពីការផ្សព្វផ្សាយដំណើរការធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រជុំទី៩ ២០១៥ | 29/04/15 | ០១ | កំពង់ធំ | មន្ទីរផែនការខេត្ត |
| 17 | ប | | | | ១.លោក តាន់ វាសនា<br>២.លោក ថុង ប៊ុនធាង | អនុប្រធានមន្ទីរ និង ប្រធានការិ- | និតិវិធីលទ្ធកម្មរបស់អង្គភាពថវិកា | ២០/០៤-០៥/០៥/១៥ | ១៥ | កំពង់ធំ | ម.ហិរញ្ញវត្ថុ |
| 18 | ប | | | | លោក ម៉ាក់ មុន្នា | ប្រធានការិ- | GIS | ០៤-០៦/០៥/១៥ | ៣ | ភ្នំពេញ | MRD/RRIP |
| 19 | ប | | | | ១.លោក សេង ជាសុខ<br>២.លោក លី សុផល<br>៣.កញ្ញា ពេជ្រ រដ្ឋា | អនុប្រធានមន្ទីរ-ការិ-ខេត្ត និង មន្ត្រី ការិ - | គម្រោងឥណទានជនបទ | ០៤-០៥/០៥/១៥ | ២ | កំពង់ចាម | MRD |
| 20 | | ស | | | ១.លោក ប្លង់ សាឡុន | ប្រធានការិ- | ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | ២១/០៥/១៥ | ១ | កំពង់ធំ | PCDM |
| 21 | | | ទ | | លោក តាន់ វាសនា | | ទស្សនៈកិច្ចសិក្សាស្តីពី | ០២-០៤/ | ៣ | ខេត្ត | AFD |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | “ការពង្រឹងសមត្ថភាពសហគមន៍ ដើម្បីធន់ទ្រាំទៅនិងគ្រោះភ័យនៃគ្រោះមហន្តរាយ” នៅអង្គការអភិវឌ្ឍន៍ធនធានមនុស្សកម្ពុជា(CHRD) | ០៦/១៥ | | បន្ទាយមានជ័យ | |
| 22 | | ស | | | លោក តាន់ វាសនា | អនុប្រធានមន្ទីរ- | ពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី “ការបន្ស៊ីផែនការសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការងារផ្គត់ផ្គង់ទឹកស្អាត និងលើកកំពស់អនាម័យជនបទ” | ១០-១២/០៦/១៥ | ៣ | សៀមរាប | MRD |
| 23 | ប | | | | ស៊ីន វុទ្ធា | ប្រធានការិ- | ផ្តល់ចំណេះដឹងមូលដ្ឋានស្តីពីការប្រែប្រួលអាកាសធាតុ និងសារៈសំខាន់នៃព្រៃឈើ | ២៨-២៩/០៥/១៥ | ០២ | កំពង់ធំ | ក្រ.បរិស្ថាន |
| | | | | | | | | | | |

## ៦-ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- ២០/០៥/១៥ បានចុះ ជ្រើសរើស និង សម្ភាសន៍អតិថិជនដែលចង់ខ្ចីលុយ ឥណទានរបស់ក្រសួង អ ជ ប បានចំនួន ១១រូបនៅភូមិ បញ្ញាជី ឃុំ ត្បូងក្រពើ ស្រុក សន្ទុក ។

## ៧-ការងារជនជាតិដើមភាគតិច

- បានចុះជួប មេភូមិ មេឃុំ មានជ័យ ស្រុក សណ្តាន់ ចំនួន ១ លើក ជាលទ្ធផល ភូមិចំនួន ៤ គឺ ភូមិរនាម រំពុះ ជាំផល និង ភូមិ ថ្មី សរុប ១៨០ គ្រួសារ ស្មើនឹង ៧៨១ នាក់ ស្រី ៤២៩ នាក់។
- បានជួបប្រជុំជាមួយក្រុមប្រឹក្សាឃុំ និងមេភូមិបង្ហាញតារាងទិន្នន័យត្រូវស្រង់ស្ថិតិជនជាតិភាគតិច និងបានដាក់ផែនការឲ្យមេភូមិស្រង់ទិន្នន័យតាមតារាងបានបង្ហាញនៅសាលាឃុំ សំបូរ ដូចខាងក្រោម÷

| ស្រុក | ឃុំ | ភូមិ | ចំនួនគ្រួសារ | ចំនួនមនុស្ស | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ប្រាសទសំបូរ | សំបូរ | កូនក្អែក | ៣១៣ | ១៥៦៥ | ៨០៣ | |
| ប្រាសាទសំបូរ | សំបូរ | ច្រម៉ាស | ១២៦ | ៦០៥ | ៣១៨ | |
| សរុប | ១ឃុំ | ២ភូមិ | ៤៣៩ | ២១៧០ | ១១២១ | |

## ៨-ការងារ Gender÷ (គ្មានសកម្មភាព)

## ៩-អង្គការក្នុង និង ក្រៅរដ្ឋាភិបាលក្រោមកិច្ចសហការជាមួយមន្ទីរ

៩.១.អង្គការ iDE ÷

- បានផលិត និង លក់ចែកចាយសម្ភារៈបង្គន់ដល់សហគមន៍ចំនួន៧០៩ឈុត។

៩.២.អង្គការស្អាតកម្ពុជា ÷ស្រុក បារាយណ៍ និង ស្រុក សន្ទុក (គ្មានរបាយការណ៍)

៩.៣.អង្គការ CARITAS ÷(គ្មានរបាយការណ៍)

៩.៤.អង្គការ សកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD) (គ្មានរបាយការណ៍)

៩.៥. CWS (គ្មានរបាយការណ៍)

៩.៦.អង្គការ Moslim Aid (គ្មានរបាយការណ៍)

៩.៧. WVC ÷ បានសហការជាមួយមន្ត្រីមន្ទីរ ទទួលបានលទ្ធផលដូចខាងក្រោម÷

- បានចុះពិនិត្យ សិក្សា ទីតាំងអណ្តូងនៅឃុំចំណារលើសម្រាប់ សាងសង់អណ្តូងថ្មី ចំនួន ១៥ ស្ថិតភូមិក្អិន ៥ ភូមិល្មុង ៤ ភូមិត្រពាំងជំរចំនួន ៤ ភូមិគរ ចំនួន ២ ភូមិផ្តោច ចំនួន ១ នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥
- ចុះពិនិត្យ សិក្សាទីតាំងនៅឃុំបន្ទាយស្ទោង សម្រាប់សាងសង់អណ្តូងថ្មីចំនួន ៩ អណ្តូង ស្ថិតភូមិឈើទាល ចំនួន ១ តាម៉ុចំនួន ២ បវេងចំនួន ២ រលួសចំនួន ២ ដូនប៉ុកចំនួន ២ និងមណ្ឌលសុខភាពបន្ទាយស្ទោង ចំនួន ១ កាលពីនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១៤
- ចុះពិនិត្យ សិក្សាទីតាំងនៅឃុំបន្ទាយស្ទោង សម្រាប់សាងសង់អណ្តូងថ្មីចំនួន ៦ អណ្តូង ស្ថិតនៅភូមិបុស្សតាឯក (សាលាបុស្សតាឯក)ចំនួន ១ និងភូមិទំពេចចំនួន ៥ កាលពីនៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៤
- ចុះពិនិត្យ សិក្សាទីតាំងនៅឃុំបន្ទាយស្ទោង សម្រាប់សាងសង់អណ្តូងថ្មីចំនួន ៧ អណ្តូង ស្ថិតនៅភូមិព្រហ្វិត ចំនួន ៧ កាលពីនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១៥
- ចុះពិនិត្យ សិក្សាទីតាំងនៅឃុំបន្ទាយស្ទោង សម្រាប់សាងសង់អណ្តូងថ្មីចំនួន ៦ អណ្តូង ស្ថិតនៅភូមិក្រយាត្បូងចំនួន ១ (តាមសាលា) និង ភូមិសង្វាតចំនួន៥នៅថ្ងៃទី ០៥ខែ មករា ឆ្នាំ ២០១៥
- ចុះពិនិត្យ សិក្សាទីតាំងនៅឃុំបន្ទាយស្ទោង សម្រាប់សាងសង់អណ្តូងថ្មីចំនួន ១៥ អណ្តូង ស្ថិតភូមិគាន្ទាក់ ចំនួន៨ និងភូមិត្រពាំងព្រីងចំនួន ៧ កាលពីនៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៥
- បានចុះរកទីតាំងជីកអណ្តូងចំនួន ៤ អណ្តូង តាមសាលាបឋមសិក្សារស្មីអង្គាញ់ ភូមិ អូររំចេក សាលាបឋមសិក្សាដូនល្អ ភូមិដូនល្អ សាលាបឋមសិក្សាប្រដិត ភូមិប្រដិត និងសាលាបឋមសិក្សាត្រាចជ្រុំ ភូមិត្រាចជ្រុំ ដែលស្ថិតនៅ ឃុំសំព្រោច ស្រុកស្ទោង ខេត្តកំពង់ធំថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥
- បានចុះផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យតាមសាលាបឋមសិក្សា(HP) នៅស្ទោងមានសិស្សានុសិស្សចូលសរុប ៥២៣ នាក់/ស្រី ២៩៩ នាក់ ឃុំចំណាក្រោមចំនួន ៦សាលា និង នៅស្រុកកំពង់ស្វាយមានសិស្សានុសិស្សចូលរួមសរុប ១៦១៧ នាក់ ស្រី ៧៨១ នាក់ ចំនួន ៥ សាលាបឋមសិក្សា
- បានចុះបំផុសស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS)នៅកំពង់ស្វាយ ភូមិជ័យ ឃុំសាន់គរ អ្នកចូលរួមសរុប ១១០ នាក់ ស្រី ៦៦ នាក់
- បានចុះប្រជុំឆ្លុះបញ្ចាំងស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS)នៅការិយាល័យ អង្គការ ស្រុកកំពង់ស្វាយ អ្នកចូលរួមសរុប ២៦ នាក់ ស្រី ១៩ នាក់ (ឃុំត្បែង គឺភូមិត្រាច ឃុំសាន់គរ គឺភូមិបល្ល័ង្ក ភូមិតាំងក្រូច និង ភូមិជ័យ)
- បានចុះផ្សព្វផ្សាយពីការលាងសំអាតដៃជាមួយសាប៊ូនៅស្រុក ប្រាសាទសំបូរបានចំនួន ៦ លើកមានអ្នកចូលរួមសរុប ៧៤៦ នាក់ស្រី ៣៤៦ នាក់
- ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ២០១៥ បំផុសស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យ CLTS នៅភូមិកុកគ្រួស ឃុំបន្ទាយស្ទោង ស្រុកស្ទោង ខេត្តកំពង់ធំ ក្នុងនោះមាន÷
    - អ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល) សរុបចំនួន៥នាក់ ស្រី ០១ នាក់
    - មាតាបិតាសិស្ស សរុបចំនួន ៤៤ នាក់ ស្រី ៣០ នាក់ កុមារសរុប ១៩ នាក់ ស្រី ១០ នាក់

គោលបំណង គឺត្រូវមានវិធានការទប់ស្កាត់ផ្លូវចម្លងរោគ អ្នកចូលរួមបានឆ្លើយថា ធ្វើបង្គន់ប្រើ លាងដៃជាមួយសាប៊ូ ផឹកទឹកស្អាត សម្អាតភូមិដ្ឋាន និងអនាម័យខ្លួនប្រាណ ។ ត្រូវតែដឹងអំពីអត្ថន័យ នៃ ពាក្យអនាម័យឲ្យបានច្បាស់គឺ ជាការស្អាតគ្មានមេរោគគ្មានជម្ងឺនិង ត្រូវប្រតិបត្តិយ៉ាង ណាឲ្យមានអនាម័យជាប្រចាំ និងចុះជម្រុញតាមខ្នងផ្ទះខ្វះអនាម័យជាពិសេសគ្រួសារគ្មានបង្គន់។

- ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០១៥ បំផុសស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យ CLTS នៅភូមិ ក្អិន ឃុំ ចំណាលើ ស្រុកស្មោង ក្នុងនោះមាន÷
  - អ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល) សរុបចំនួន ៦ នាក់ ស្រី 0 នាក់
  - មាតាបិតាសិស្សសរុបចំនួន ៦៦ នាក់ ស្រី ៤៤ នាក់និងកុមារសរុប ៣៩ នាក់ ស្រី ២១ នាក់
- ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០១៥ ប្រជុំជាមួយគណៈកម្មការអនាម័យភូមិ ដើម្បីឆ្លុះបញ្ចាំងពី ដំណើរការ CLTS រីកចម្រើន នៅក្លឹបល្ហុង ភូមិល្ហុង គរ និងភូមិផ្លោច ឃុំចំណារលើ ស្រុកស្មោង
- ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១៥ បានចុះផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យតាមសាលារៀន (HP) នៅសាលាបឋមសិក្សាពាមអាទិត្យ មានសិស្សានុសិស្សសរុបចំនួន៤៤ នាក់ស្រី ២៨ នាក់និងសាលាបឋមសិក្សាអូរអង្គរ មានសិស្សានុសិស្សសរុបចំនួន ៨៥ នាក់ស្រី ៦២ នាក់ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ
- ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៥ បានចុះផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យតាមសាលារៀន (HP) នៅសាលាបឋមសិក្សាត្រពាំងព្រីងមានសិស្សានុសិស្សសរុបចំនួន ១២៧ នាក់ស្រី ៦៥ នាក់ និងសាលាបឋមសិក្សាស្រែវាល មានសិស្សានុសិស្សសរុបចំនួន ១១៩ នាក់ស្រី ៥៤ នាក់ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ
- ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០១៥ បានចុះផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យតាមសាលារៀន (HP) នៅសាលាបឋមសិក្សាវាលថ្នល់ មានសិស្សានុសិស្សសរុបចំនួន ២៥៧ នាក់ស្រី ១៣៧ នាក់ និងនៅសាលាបឋមសិក្សាសាគ្រាម មានសិស្សានុសិស្សសរុបចំនួន ៣៥០ នាក់ ស្រី ១៩១ នាក់ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ
- ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៥ បានចុះផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យតាមសាលារៀន (HP) នៅសាលាបឋមសិក្សាត្រពាំងព្រីង មានសិស្សានុសិស្សសរុបចំនួន ៩០ នាក់ស្រី ៤៤ នាក់និងនៅសាលាបឋមសិក្សាគាន្ទាក មានសិស្សានុសិស្សសរុបចំនួន ២២៩ នាក់ស្រី ១០៨ នាក់ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ
- ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៥ បានចុះបណ្តុះបណ្តាលស្តីពីការបំផុសសហគមន៍ដឹកនាំ អនុវត្តអនាម័យក្នុងនោះមាន អ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល) សរុបចំនួន៣នាក់ស្រី ០១ នាក់ មាតាបិតាសរុប ៣៩ នាក់ ស្រី ៣៣ នាក់ និងកុមារសរុប ១១ នាក់ នៅភូមិបុស្សធំ ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ
- ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ បានចុះបណ្តុះបណ្តាលស្តីពីការបំផុសសហគមន៍ ដឹកនាំអនុវត្តអនាម័យក្នុងនោះមានអ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល) សរុបចំនួន ៥ នាក់ ស្រី ២ នាក់ មាតាបិតាសរុប ៦២ នាក់ ស្រី ៣៧ នាក់ និងកុមារសរុប ២៤ នាក់ នៅភូមិព្រិច ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ
- ថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០១៥ បានចុះបណ្តុះបណ្តាលស្តីពីការបំផុសសហគមន៍ដឹកនាំអនុវត្តអនាម័យ ក្នុង

នោះមានអ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល) សរុបចំនួន ៤ នាក់ស្រី ២ នាក់ មាតាបិតាសរុប ៤៨ នាក់ ប្រុស ១២ នាក់ និងកុមារសរុប ០៨ នាក់ នៅភូមិព្រហ៊ូត ឃុំផាន់ញើម ស្រុកប្រាសាទបល្ល័ង្គ

- ថ្ងៃទី ០៤ ខែមីនាឆ្នាំ ២០១៥ បានចុះបណ្តុះបណ្តាលស្តីពី ការបំផុសសហគមន៍ដឹកនាំអនុវត្តអនាម័យ ក្នុងនោះមានអ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល) សរុបចំនួន៣នាក់/ស្រី ០០ នាក់ មាតាបិតាសរុបចំនួន ៣៦ នាក់ ស្រី ២០ នាក់ និងកុមារសរុប ០៥ នាក់ នៅភូមិគន្ទាក់ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ
- ថ្ងៃទី ០៥ ខែមីនា ឆ្នាំ ២០១៥ បានចុះបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងប្រភពទឹកស្អាតជាមួយគណៈកម្មការថែទាំអណ្តូង និងប្រើប្រាស់ ភូមិត្រពាំងព្រីង សរុប ១១ នាក់ស្រី ៤នាក់ និងគណៈកម្មការថែទាំ និងប្រើប្រាស់អណ្តូង ភូមិសង្ហាត សរុប ១៥ នាក់ស្រី ០៥ នាក់ នៅការិយាល័យអង្គការ WVC ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ
- ថ្ងៃទី ០៦ ខែមីនា ឆ្នាំ ២០១៥ បានចុះបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងប្រភពទឹកស្អាត ជាមួយគណៈកម្មការថែទាំ និងប្រើប្រាស់អណ្តូង ភូមិព្រហ៊ូត សរុប ១៥ នាក់ស្រី ០៦ នាក់ និងគណៈកម្មការថែទាំ និងប្រើប្រាស់ អណ្តូង ភូមិគាន្ទាក សរុប ២៣ នាក់ស្រី ០៩ នាក់ នៅការិយាល័យ WVC ស្រុក ប្រាសាទបល្ល័ង្គ ឃុំក្រយា
- ថ្ងៃទី ១១ ខែមីនាឆ្នាំ ២០១៥ បានចូលរួមចុះត្រួតពិនិត្យនិងវាយតម្លៃភូមិ ODF ក្នុងនោះមាន អ្នកចូលរួមសរុប ១៥ នាក់ ស្រី ៥ នាក់ នៅភូមិផ្លោច ឃុំចំណារលើ
- ថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០១៥ បានចុះបណ្តុះបណ្តាលស្តីពីការបំផុសសហគមន៍ដឹកនាំអនុវត្តអនាម័យក្នុងនោះមានអ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល) សរុបចំនួន ១០ នាក់/ស្រី ០៧ នាក់ (ក្នុងនោះមានអាជ្ញាធរភូមិ ២ នាក់) មាតាបិតាសរុបចំនួន ១៦ នាក់ស្រី ១៥ នាក់ និងកុមារសរុប ៣៥ នាក់ ស្រី ១៧ នាក់នៅភូមិក្រសាំងជ្រុំជើង ឃុំសំព្រោច ស្រុកស្ទោង
- ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ បានចុះបណ្តុះបណ្តាលស្តីពីការបំផុសសហគមន៍ដឹកនាំអនុវត្តអនាម័យ ក្នុងនោះមានអ្នកសម្របសម្រួលអនាម័យភូមិសរុបចំនួន ១១ នាក់ស្រី ១០ នាក់ មាតាបិតាសរុបចំនួន ២៩ នាក់ស្រី ២៨ នាក់ និងកុមារសរុប ២៦ នាក់ស្រី ១៨ នាក់ នៅភូមិក្រសាំងជ្រុំត្បូងឃុំសំព្រោចស្រុកស្ទោង
- ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥ បានចុះបណ្តុះបណ្តាលស្តីពីការបំផុសសហគមន៍ដឹកនាំ អនុវត្តអនាម័យក្នុងនោះមានអ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល)សរុបចំនួន ១៣ នាក់/ស្រី ១០ នាក់ មាតាបិតាសរុបចំនួន ៣៦ នាក់ស្រី ៣១ នាក់ និងកុមារសរុប ៣៦ នាក់ស្រី ២២ នាក់នៅភូមិដូនល្អ ឃុំសំព្រោចស្រុកស្ទោង
- ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៥ បានចុះបណ្តុះបណ្តាលស្តីពីការបំផុសសហគមន៍ដឹកនាំអនុវត្តអនាម័យ ក្នុងនោះមានអ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល) សរុបចំនួន ៤ នាក់ស្រី ៣ នាក់ មាតាបិតាសរុបចំនួន ៣៩ នាក់ស្រី ៣៧ នាក់ និងកុមារសរុប ១៥ នាក់ស្រី ១៣ នាក់ នៅភូមិអូរចេកឃុំសំព្រោជស្រុកស្ទោង
- ចូលរួមបានចំនួន ០៨ លើក ស្តីពីការបំផុសសហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS) នៅភូមិបុស្សធំ ភូមិ

ព្រិច ភូមិ គាន្ទាក ភូមិ ព្រហូត ក្នុងឃុំក្រយា ឃុំសាគ្រាម និងឃុំផាន់ញើម ស្រុកប្រា-បល័្លង្គ និងភូមិក្រសាំងជ្រុំជើង ក្រសាំងជ្រុំត្បូង ដូនល្អ អូរចេក ស្រុកស្ទោង មានអ្នកចូលរួមសរុបចំនួន ៥៩៦ នាក់ ស្រី ៤១៤ នាក់

- បានចូលរួមផ្សព្វផ្សាយស្តីពីការងារលើកកម្ពស់អនាម័យ (HP) ចំនួន ០៨ សាលា ដល់ សិស្សានុសិស្សសាលាបឋមសិក្សាពានអាទិត្យ អូរអង្គ ត្រពាំងព្រីង អូរខ្សង់ ស្រែវាល ថ្នល់ សាគ្រាម និង គន្ទាក ក្នុងឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ដោយមានអ្នកចូលរួមចំនួន ១,៤៨២ នាក់ ស្រី ៧២៩ នាក់
- បានប្រជុំឆ្លុះបញ្ចាំងពីការងារគ្រប់គ្រងទឹកស្អាត ដល់ក្រុមប្រើប្រាស់ទឹកស្អាត បានចំនួន ០២ លើកនៅភូមិសង្ហាត-ត្រពាំងព្រីង-ប្រហូត-គន្ទាក ក្នុងឃុំសាគ្រាម និងឃុំផាន់ញើម ស្រុកប្រាសាទបល្ល័ង្គ ដោយមានអ្នកចូលរួមចំនួន ៦៣ នាក់ ស្រី ២៤ នាក់
- បានចុះត្រួតពិនិត្យវាយតម្លៃភូមិផ្លោច ឃុំចំណារលើស្រុកស្ទោង ខេត្តកំពង់ធំ បាន ចំនួន ០១ លើក ក្នុងការពិនិត្យផ្ទៀងផ្ទាត់ ដើម្បីដាក់បញ្ចូលភូមិ ODF ដែលមានអ្នកចូលរួមពីក្រុមការងារអង្គការទស្សនៈពិភពលោក មន្ទីរអភិវឌ្ឍន៍ខេត្តពីរនាក់ គឺលោក តាន់ វាសនា និងលោកស៊ុន ជួត ក្រុមអនាម័យភូមិបានចូលរួមចំនួន ០៦ នាក់ យុវជន ០១ នាក់ មេឃុំ ០១ នាក់ លទ្ធផលសម្រេចបាន ត្រូវដាក់បញ្ចូលភូមិផ្លោច ជាភូមិ ODF
- លោកអនុប្រធានមន្ទីរទទួលបន្ទុកសុខភាពបឋមជនបទ និងមន្ត្រីប្រធានការិយាល័យសុខភាពបឋមជនបទ បានចូលរួមចុះពិនិត្យ និងផ្ទៀងផ្ទាត់ភូមិ ODF នៅភូមិបុស្សធំ ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ បានចំនួន ០១ លើក មានអ្នកចូលរួមចំនួន ០៩ នាក់ គឺមានប្រធានតំបន់អង្គការWVC ០១ នាក់ ជនបង្គោលអនាម័យភូមិ ០៤ នាក់ ប្រធានភូមិ ០១ នាក់ អនុភូមិ ០១ នាក់ និងមន្ទីរអភិវឌ្ឍន៍ ០២ នាក់ លទ្ធផលបាន ១៣៥ គ្រួសារ
- ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៥ បានចុះពិនិត្យ និងផ្ទៀងផ្ទាត់ភូមិបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល លើក ទី ១ (ODF) នៅក្នុង ឈ្មោះភូមិៈ បុស្សធំ ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ដែលមាន÷
    - មានចំនួនអ្នកចូលរួម ៥៨៦នាក់ ស្រី ២៩៦ នាក់
    - ចំនួនគ្រួសារសរុបៈ ១៣៥ គ្រួសារ ចំនួនខ្នងផ្ទះ ១៣១ ខ្នងផ្ទះ (បានចុះអង្កេតផ្ទាល់)
    - ចំណាកស្រុក÷ ២៤ ខ្នងផ្ទះ ស្មើនឹង ១៨,៣២%
    - ចំនួនខ្នងផ្ទះមានបង្គន់ក្នុងពេលបច្ចុប្បន្ន ចំនួន ១១៣ ខ្នងផ្ទះ ស្មើនឹង ៨៦,២៥%
    - ចំនួនខ្នងផ្ទះមានអណ្តូងក្នុងពេលបច្ចុប្បន្ន ចំនួន ៣៩ អណ្តូង ស្មើនឹង ២៩,៧៧%
    - ការបរិច្ឆេទភូមិដែលបានធ្វើការបំផុស CLTS និងផ្គត់ផ្គង់ទឹកស្អាត ចាប់ពីឆ្នាំ ២០១៥
- ថ្ងៃទី២៤ ដល់២៥ ខែមីនា ឆ្នាំ ២០១៥ បានចុះត្រួតពិនិត្យការសាងសង់អណ្តូងល្ង ចំនួន ២៨ អណ្តូង នៅឃុំ ក្រយា សាគ្រាម ផាន់ញើម ស្រុក ប្រាសាទបល្លង្គ សម្រេចបាន ៧៥%
- ថ្ងៃទី០៧ មេសា ឆ្នាំ ២០១៥ បានចុះបំផុសសហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS) ក្នុងនោះ÷
    1. អ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល) សរុបចំនួន ៧ នាក់ ស្រី ៥ នាក់

2. មាតាបិតា (ប្រជាជន) សរុបចំនួន ២៥ នាក់ស្រី ២២ នាក់

3. កុមារសរុប ២០ នាក់ ស្រី ១៩ នាក់ នៅភូមិដូនល្អ ឃុំសព្រោជ ស្រុកស្ទោង

- ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០១៥ បានចុះបំផុសសហគមន៍ដឹកនាំអនុវត្តអនាម័យ(CLTS) ក្នុងនោះ÷

1. លោក មេភូមិ អូរំចេក

2. អ្នកសម្របសម្រួលអនាម័យភូមិ (ជនបង្គោល) សរុបចំនួន ៧ នាក់ស្រី ៥ នាក់

3. មាតាបិតា(ប្រជាជន) សរុបចំនួន ៤០ នាក់ស្រី ៣៨ នាក់

4. កុមារសរុប ២២ នាក់ស្រី ១៦ នាក់ នៅ ភូមិអូរំចេក ឃុំ សព្រោច ស្រុក ស្ទោង។

- បានចុះ អប់រំផ្សព្វផ្សាយ ពីការប្រើប្រាស់ទឹកស្អាត និងអនាម័យ ចំនួន ០១ លើក រយៈពេល ២ ថ្ងៃ នៅភូមិចំនួនពីរ គឺភូមិព្រៃម្រីយ៍ និងភូមិព្រិច ឃុំផាន់ញើម និងឃុំសាគ្រាម ក្នុងស្រុកប្រាសាទបល្ល័ង្គ មានអ្នកចូលរួមសរុបចំនួន ៨៦ នាក់ ស្រី ៦៥ នាក់

- ចុះវាយតម្លៃភូមិបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល នៅភូមិបុស្សធំ ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ នៅថ្ងៃទី ០៨-០៩ ខែ មិថុនា គ.ស ២០១៥ កាលបរិច្ឆេទទទួលបានការចាប់ផ្តើមបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ឆ្នាំ ២០១៣ ចំនួនគ្រួសារមានបង្គន់នាពេលបច្ចុប្បន្នសរុប ១២៣ បង្គន់បង្គន់ចាក់ទឹក ១២២ បង្គន់ បង្គន់ស្ងួត ០១ បង្គន់ និងគ្រួសារដែលប្រើប្រាស់បង្គន់រួមមានចំនួន ០៨ គ្រួសារ

៩.៨. អង្គការ ពន្លឺអភិវឌ្ឍន៍ (APA) (គ្មានរបាយការណ៍)

៩.៩. អង្គការ ស្រែខ្មែរ ÷ការចុះសម្របសម្រួលក្រុមសន្សំប្រាក់÷

មន្ត្រីរបស់អង្គការស្រែខ្មែរ ចុះធ្វើការសម្របសម្រួលលើក្រុមសន្សំជាប្រចាំ រៀងរាល់ពីរដងក្នុងមួយខែតាមក្រុមនីមួយៗ ដើម្បីពិនិត្យ និងតាមដានលើដំណើរការរបស់ក្រុមសន្សំ។ ចាប់ពីថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៥ មន្ត្រីបានបណ្តុះបណ្តាលក្រុមសន្សំប្រាក់បានចំនួន ៤២ វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ៦១១ នាក់ ក្នុងនោះស្ត្រីមានចំនួន ៥៩២ នាក់ ការបណ្តុះបណ្តាលនេះផ្តោតទៅលើ ការចុះបញ្ជីសាច់ប្រាក់ ការគ្រប់គ្រងប្រាក់កម្ចី ការរៀបចំសមតុល្យសាច់ប្រាក់។

សង្ខេបសកម្មភាពបណ្តុះបណ្តាលក្រុមសន្សំ

| ស្រុក | ឃុំ | ភូមិ | ចំនួនលើក | អ្នកចូលរួមសរុប | អ្នកចូលរួមជាស្ត្រី |
|---|---|---|---|---|---|
| កំពង់ស្វាយ | សានគរ | សានគរខ | ៣ | ៤២ | ៣៩ |
| | | តាំងក្រូច | ៣ | ៤៣ | ៤៣ |
| | ត្រពាំងឫស្សី | ព្រៃព្រាលក | ៣ | ៤៧ | ៤៣ |
| ក្រុងស្ទឹងសែន | ស្រយ៉ូវ | ពុកយុក | ៤ | ៦៤ | ៦២ |
| | | ស្រយូវជើង | ៣ | ៥៦ | ៥៦ |
| | | ត្រពាំងវែង | ៣ | ៤៤ | ៤៤ |
| ប្រាសាទបាល័ង្គ | សាលាវិស័យ | ដងអន្ទាក់ | ៤ | ៤៨ | ៤៦ |

| | | | | | |
|---|---|---|---|---|---|
| ប្រាសាទសំបូរ | សំបូរ | ជាយសំពៅ | ៣ | ៤៥ | ៤២ |
| | | អូរគ្រកែ | ៣ | ៤៧ | ៤៧ |
| | | សំបូរ | ៣ | ៣៨ | ៣៨ |
| សន្ទុក | កកោះ | ត្បូងក្រពើ | ២ | ៣២ | ៣២ |
| | ទីពោ | និម្មិត | ៤ | ៥២ | ៥២ |
| | | តាព្រាច | ៤ | ៥៣ | ៥២ |
| សរុប | | | ៤២ | ៦១១ | ៥៩៦ |

**ការរៀបចំទិវាបង្ហាញ÷សកម្មភាពនេះ** ត្រូវបានធ្វើជាមួយកសិករទទួលផល និងអ្នកដែលចាប់អារម្មណ៍លើសកម្មភាពគម្រោង ដោយមានការចូលរួមសម្របសម្រួលពីមន្ត្រីគម្រោងកម្ពុជា-ហាវ៉េស និងសហការជាមួយអាជ្ញាធរមូលដ្ឋាន។ គិតត្រឹម ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៥ ការរៀបចំទិវាបង្ហាញនេះ បានសម្រេចចំនួន ៧ ព្រឹត្តិការណ៍ ដោយមានអ្នកចូល រួមសរុប ចំនួន ២២០ នាក់ ក្នុងនោះមានស្ត្រី ១៦១ នាក់។ គោលបំណងនៃទិវានេះ គឺបង្ហាញពីបច្ចេកទេសដាំដុះបន្លែ ប្រមូលផលបន្លែ ការស្រោចស្រពបន្លែដោយប្រើប្រព័ន្ធដំណក់ទឹក ការប្រើប្រាស់ជី វិធានការចម្រុះគ្រប់គ្រងដំណាំ ការគ្រប់គ្រងទឹកលើដំណាំស្រូវ ការ ធៀបទិន្នផលស្រូវ និងការទុកដាក់ស្រូវ បន្ទាប់ពីប្រមូលផលរួច។

| កាលបរិច្ឆេទ | ស្រុក | ឃុំ | ភូមិ | ព្រឹត្តិការណ៍ | អ្នកចូលរួមសរុប | អ្នកចូលរួមជាស្ត្រី |
|---|---|---|---|---|---|---|
| ១១-មីនា-២០១៥ | កំពង់ស្វាយ | ជ័យ | មហ៉ែរ | ១ | ៤៤ | ៣៦ |
| ២៣-កុម្ភៈ-២០១៥ | កំពង់ស្វាយ | កំពង់ស្វាយ | តាធាវ | ១ | ៣៤ | ២៥ |
| ០៤-មីនា-២០១៥ | កំពង់ស្វាយ | កំពង់ស្វាយ | ត្នោត | ១ | ១៧ | ១០ |
| ២៥-កុម្ភៈ-២០១៥ | កំពង់ស្វាយ | ក្តីដូង | ពាមក្រែង | ២ | ៧៧ | ៥៤ |
| ១២- មីនា-២០១៥ | កំពង់ស្វាយ | សានគរ | បាល័ង្គ | ១ | ២៥ | ១៦ |
| ១៣- មីនា-២០១៥ | ប្រាសាទសំបូរ | សំបូរ | អាត់ស្វ៊ | ១ | ២៣ | ២០ |
| សរុបរួម | | | | ៧ | ២២០ | ១៦១ |

- **ការបណ្តុះបណ្តាល÷សកម្មភាពនេះ** ត្រូវបានធ្វើជាមួយកសិករទទួលផល និងអ្នកដែលចាប់អារម្មណ៍លើសកម្មភាពគម្រោង ដោយមានការចូលរួមសម្របសម្រួលពីមន្ត្រីគម្រោងកម្ពុជា-ហាវ៉េស ដែលសកម្មភាពនេះភាគច្រើនមានទម្រង់ ជា ក្រុមតូចៗ និងមួយចំនួនទៀតជាក្រុមធំ ដើម្បីផ្តល់ចំណេះដឹងដល់កសិករទទួលផល។ សម្រាប់ខែមីនា នេះ ក្រុមការងាររបស់អង្គការស្រែខ្មែរសម្រេចបាន ១៩០ វគ្គបណ្តាល ដោយមានអ្នកចូលរួមសរុប ១០៥៥ នាក់ ក្នុងនោះស្ត្រីមានចំនួន ៧២២ នាក់។ ការបណ្តុះបណ្តាលនេះផ្តោតទៅលើ -បច្ចេកទេសដាំដុះបន្លែ÷ ការរៀបចំដី ការរៀបចំល្បាយដីបណ្តុះកូនដំណាំ វិធានការការពារនិងកំចាត់សត្វល្អិត ការគ្រប់គ្រងទឹកសម្រាប់ ដំណាំ ការដាក់ជីលើដំណាំ ការតាក់តែងមែក ការណែនាំបង្ហាញពីអត្តសញ្ញាណ ជំងឺ បាក់តេរី វីរុស សត្វល្អិត។ -បច្ចេកទេសដំណាំស្រូវ÷ ការប្រើប្រាស់ឧបករណ៍ព្រួសស្រូវ ការសម្រាំងគ្រាប់ពូជស្រូវមុនព្រួស គុណវិបត្តនៃ ស្មៅក្នុងស្រែ ការប្រមូលផល និង ទុកដាក់ក្រោយពេលប្រមូលផល។

| ស្រុក | ឃុំ | ភូមិ | ព្រឹត្តិការណ៍ | អ្នកចូលរួមសរុប | អ្នកចូលរួមជាស្ត្រី |
|---|---|---|---|---|---|
| កំពង់ស្វាយ | ជ័យ | មហារ៉ | ១២ | ៥៥ | ៣០ |
| | | តាធាវ | ៩ | ៤៨ | ៣៥ |
| | ក្ដីដូង | អូរសិប្ដូរ | ២ | ២៤ | ២ |
| | | ពាមក្រែង | ៦ | ៦៣ | ៣៧ |
| | សានគរ | បាល័ង្គ | ១៧ | ៨៦ | ៦១ |
| | | សានគរខ | ៤ | ១៦ | ១០ |
| | | តាំងក្រូច | ១៤ | ៨៤ | ៧៥ |
| | ត្រពាំងឬស្សី | ព្រៃព្រាលក | ១៦ | ៧៩ | ៣២ |
| | | ព្រៃព្រាលខ | ១៤ | ៧៤ | ៦១ |
| ក្រុងស្ទឹងសែន | អូរកន្ធរ | អូរកន្ធរត្បូង | ១ | ១១ | ៣ |
| | ស្រយូវ | ពោធិតាអ៊ុន | ០ | ០ | ០ |
| | | ស្រយ៉ូវជើង | ០ | ០ | ០ |
| | | ស្រយ៉ូវត្បូង | ២ | ២១ | ៦ |
| | | ត្រពាំងវែង | ១២ | ៦០ | ៣៨ |
| ប្រាសាទបាល័ង្គ | សាលាវិស័យ | ជ័យ | ១ | ១០ | ៣ |
| | | ដងអន្ទាក់ | ៩ | ៤៣ | ៣៦ |
| | | ត្រពាំងក្រោល | ០ | ០ | ០ |
| ប្រាសាទសំបូរ | សំបូរ | អាត់ស្វ៊ | ៨ | ៥០ | ៤៤ |
| | | ជាយសំពៅ | ១៥ | ៧៣ | ៥៥ |
| | | អូរគ្រូកែ | ៧ | ៣៣ | ២៧ |
| | តាំងក្រសៅ | ជាំ | ៨ | ៣៦ | ៦ |
| សន្ទុក | កកោះ | ត្បូរក្រពើ | ១១ | ៥៣ | ៨៩ |
| | ទីពោ | និម្មិត | ៩ | ៤៥ | ៣៨ |
| | | សំរោង | ០ | ០ | ០ |
| | | តាព្រាច | ៩ | ៤៣ | ៣៥ |
| | ត្បូងក្រពើ | ពញ្ញាជី | ១ | ១៣ | ៦ |
| ស្ទូង | បន្ទាយស្ទូង | បេង | ១ | ១១ | ៩ |
| | | ឈើទាល | ១ | ១១ | ៦ |
| | ចំណាលើ | ស្រង់ | ១ | ១៣ | ៨ |
| សរុបរួម | | | ១៩០ | ១០៥៥ | ៧២២ |

**-ការចុះសម្របសម្រួលក្រុមសន្សំប្រាក់÷** មន្ត្រីរបស់អង្គការស្រែខ្មែរ ចុះធ្វើការសម្របសម្រួលលើក្រុមសន្សំជាប្រចាំ រៀងរាល់ពីរដងក្នុងមួយខែ តាមក្រុមនីមួយៗ ដើម្បីពិនិត្យ និងតាមដានលើដំណើរការរបស់ក្រុមសន្សំ។ ចាប់ពីថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៥ រហូតដល់ថ្ងៃទី ២០ ខែមិនា ឆ្នាំ ២០១៥។ មន្ត្រីបានបណ្តុះបណ្តាលជាក្រុមសន្សំប្រាក់បានចំនួន ៣០ វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ៣១៦ នាក់ ក្នុងនោះស្ត្រីមានចំនួន ៤០៩ នាក់។ ការបណ្តុះបណ្តាលនេះផ្តោតទៅលើ ការចុះបញ្ជីសាច់ប្រាក់ ការគ្រប់គ្រងប្រាក់កម្ចី ការរៀបចំសមតុល្យសាច់ប្រាក់។

**-ទិវាចំអិនបង្ហាញ÷មន្រ្តីរបស់អង្គារស្រែខ្មែរ** បានរៀបចំទិវាចំអិនបង្ហាញនៅភូមិគោលដៅចំនួន ៦ភូមិ។ សកម្មភាពនេះគឺក្នុង គោលបំណងចង់អោយបងប្អូនប្រជាកសិករយល់ដឹងកាន់តែច្បាស់ពីអត្ថប្រយោជន៍នៃការហូបបន្លែច្រើនមុខ និងមានអាហាររូបត្ថម្ភខ្ពស់។ ជាលទ្ធផលក្រុមការងារសំរេចបានចំណួន ៦ បង្ហាញ នៅភូមិ ពុកយុក ស្រយូវជើង ត្បូងក្រពើ ព្រៃព្រាលក ព្រៃព្រាលខ និងភូមិសានគរខ ដែលមានអ្នកចូលរួមសរុប ចំនួន ១២៩ នាក់ ក្នុងនោះស្រីមានចនួន ១២៥ នាក់។

**៩.១០. អង្គការ ADRA** (គ្មានរបាយការណ៍)

**៩.១១. អង្គការ HOM**

មន្ត្រីមន្ទីរពីររូបជាគ្រូបង្គោលបានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្រុងស្ទឹងសេន ដែលអ្នកចូលរួមមកពីមន្ត្រីរាជការជុំវិញក្រុងចំនួន ២២ នាក់ ស្រី ៦ នាក់ (២៣-២៦ ខែមីនា ឆ្នាំ ២០១៥ )។

**៩.១២. អង្គការ ESSD**

មន្ត្រីមន្ទីរពីររូបជាគ្រូបង្គោលបានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី ការកាត់បន្ថយញហានិភ័យនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅសាលាស្រុក ប្រាសាទសំបូរ ដែលអ្នកចូលរួមមកពីមន្ត្រីរាជការជុំវិញស្រុក ចំនួន ២៤ នាក់ ស្រី ០៧ នាក់ (03-06 ខែ មីនា ឆ្នាំ ២០១៥)។

**៩.១៣. អង្គការ ទឹកស្អាត១០០១**

នៅតាមទីតាំងស្ថានីយ៍ផលិតទឹកសុទ្ធក្នុងខេត្ត មានចំនួន ៦ កន្លែង មានសមាជិកគណៈកម្មការគ្រប់គ្រង ៣៦ នាក់ ស្រី ១៨ នាក់ មានប្រជាពលរដ្ឋទិញទឹកប្រើប្រាស់ជាអចិន្ត្រៃយ៍ចំនួន ២.៦៦២ គ្រួសារ នៅក្នុងរយៈពេលបីខែនេះសាលារៀនចំនួន ១៧ សាលាបានទិញទឹកហូបចំនួន ៦.៩២៩ ប៊ីដុង។

**៩.១៤. អង្គការ** CGA

មន្ត្រីមន្ទីរបានចូលរួមបណ្តុះបណ្តាលពង្រឹង គ អ ភ កាលពីថ្ងៃទី ១១-១២ ខែ មីនា ២០១៥ បានចំនួន ១វគ្គ ចំនួន ៥ភូមិ គឺ កណ្តើលចាស់ សំភី ប្រាសាទ ជះ និង ភូមិ សំរ៉ុង ឃុំ ព្រះដំរី ស្រុក ស្ទោង មានអ្នក ចូលរួមសរុប ១៩៧ នាក់ ស្រី ១៦១ នាក់ ។

**១០-កម្មវិធី និងគម្រោង**

**១០.១-គម្រោងផ្គត់ផ្គង់ទឹកនិងអនាម័យជនបទទី ២** (RWSSSP-2) ( មន្ត្រីចំនួន ១០ នាក់)

- មន្ត្រីគម្រោងចំនួន ០៤ នាក់បានចូលរួមជាមួយមន្ត្រីជំនាញអង្គភាពគ្រប់គ្រងគម្រោងដឹកនាំដោយលោក ចេង ដូរ៉ាន់ បើកវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្រសាងសង់ ជួសជុលបង្គន់លិចទឹក នៅឃុំមានជ័យ ស្រុក

សណ្ដាន់ មានអ្នកចូលរួម ១៦ នាក់ ស្រី ៤ នាក់ (១៤/០១/១៥)

- បានចុះបណ្ដុះបណ្ដាលអំពីការស្រង់ និង ប្រមូលទិន្នន័យគម្រោងនៅឃុំ មានជ័យ មានរិទ្ធ និង ឃុំ បឹង ដល់ VDC CC WSUG ដែលមានអ្នកចូលរួមសរុប ៤៧២ នាក់ ស្រី ២៧១ នាក់
- ថ្ងៃទី២៣-២៦ខែ មេសា ឆ្នាំ ២០១៥ មន្ត្រីគម្រោងថ្នាក់ជាតិ ដឹកនាំដោយលោក **ចេង ដូរ៉ាន់បានចុះជម្រុញការសាងសង់បង្គន់អនាម័យតាមខ្នងផ្ទះ** នៅឃុំ មានជ័យ និង ឃុំ មានរិទ្ធ។
- ក្រុមហ៊ុន Golden hall services Co. LTD បានចុះវាយតម្លៃបញ្ចប់គម្រោងរយៈពេល៧ថ្ងៃចាប់ពីថ្ងៃទី ០១ ដល់ ថ្ងៃទី ៧ ខែ ឧសភា ២០១៥ ក្រុមគោលដៅមាន÷ ភូមិចំនួន ៧ ក្នុងនោះភូមិគោលដៅរបស់គម្រោងមាន ៥ភូមិ និង ក្រៅគោលដៅមាន២ភូមិ ស្ថិតក្នុងឃុំ ទីពោ ស្រុក សន្ទុក និង ឃុំ ស្រយ៉ូវ ក្រុង ស្ទឹងសែន។
- ឃុំ មានជ័យ ស្រុក សណ្ដាន់ចំនួន ១.២០៣ បង្គន់ បានផ្ដល់សម្ភារៈបង្គន់អនាម័យជូនសហគមន៍បាន ១០០% សហគមន៍ចូលរួមសាងសង់បានចំនួន ១.០៥៩ បង្គន់
- ឃុំ មានរិទ្ធ ស្រុក សណ្ដាន់ ចំនួន ១.១២៩ បង្គន់ បានផ្ដល់សម្ភារៈបង្គន់អនាម័យជូន សហគមន៍ បាន ១០០% សហគមន៍ចូលរួមសាងសង់បានចំនួន ៨៦៣ បង្គន់ (ខែនេះមិនមានកំណើន)។

**១០.២-គម្រោងផ្លូវក្រាលកៅស៊ូ** (RRIP-2) (មន្ត្រីចំនួន ០៤ នាក់) (គ្មានសកម្មភាព)

**១០.៣-កម្មវិធី** WFP (ផ្លូវជីស) (មន្ត្រីចំនួន ០៤ នាក់) ការងារស្បៀងសម្រាប់ទ្រព្យធន

| ទីតាំងគម្រោង | | | ប្រភេទគម្រោង | ប្រវែង (ម) | អ្នកចូលរួម | | ស្បៀង(តោន) | | លទ្ធផល (%) |
|---|---|---|---|---|---|---|---|---|---|
| ស្រុក | ឃុំ | ភូមិ | | | ស្រី | សរុប | ស្នើសុំ | អនុម័ត | |
| ប្រាសាទបល្ល័ង្គ | សាលាវិស័យ | ចំណារ | ទំនប់សង់ថ្មី | 898 | 96 | 385 | 10.460 | 10.460 | 50% |
| ប្រាសាទបល្ល័ង្គ | សាលាវិស័យ | បុស្ស ស្រមោច | ទំនប់សង់ថ្មី | 724 | 87 | 380 | 7.210 | 7.210 | 50% |
| កំពង់ស្វាយ | ក្ដីដូង | ពាមគ្រែង | ផ្លូវលំសង់ថ្មី | 1.157 | 154 | 500 | 19.390 | 19.390 | 60% |
| ស្ទោង | សំព្រោជ | ត្រាចជ្រុំ | ផ្លូវលំសង់ថ្មី | 650 | 226 | 945 | 12.150 | 12.150 | 50% |
| ប្រាសាទសំបូរ | ឈូក | ត្រពាំងសាលា | ផ្លូវលំជួសជុល | 683 | 164 | 665 | 10.530 | 10.530 | 20% |
| ប្រាសាទសំបូរ | សំបូរ | កូនក្អែក | ផ្លូវលំសង់ថ្មី | 1.107 | 380 | 1535 | 19.520 | 19.520 | 35% |
| ប្រាសាទសំបូរ | ស្រើង | ស្វាយ | ទំនប់សង់ថ្មី | 1.111 | 131 | 515 | 17.060 | 17.060 | 40% |
| ប្រាសាទសំបូរ | ស្រើង | ទំនប់ | ទំនប់សង់ថ្មី | 1.724 | 226 | 1260 | 23.630 | 23.630 | 40% |
| ស្ទឹងសែន | ស្រយ៉ូវ | ស្រយ៉ូវជើង | ផ្លូវលំសង់ថ្មី | 961 | 236 | 590 | 19.250 | 19.250 | 45% |
| សន្ទុក | ត្បូងក្រពើ | ចុងដា | ផ្លូវលំសង់ថ្មី | 781 | 139 | 615 | 17.220 | 17.220 | 70% |
| សន្ទុក | ត្បូងក្រពើ | កាលមេឃ | ផ្លូវលំសង់ថ្មី | 1.231 | 184 | 550 | 22.720 | 22.720 | 65% |
| ស្ទោង | សំព្រោជ | ស្លាក់ក្រាញ់ | ផ្លូវលំសង់ថ្មី | 1.322 | 224 | 890 | 24.760 | 24.760 | 45% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| កំពង់ស្វាយ | កំពង់ស្វាយ | ត្នោត | ផ្លូវលំសង់ថ្មី | 646 | 192 | 570 | 16.910 | 16.910 | 60% |
| កំពង់ស្វាយ | កំពង់ស្វាយ | ឥន្ទកុមារ | ផ្លូវលំសង់ថ្មី | 1.050 | 215 | 645 | 19.880 | 19.880 | 60% |
| ស្ទោង | ចំណាក្រោម | ចំណាក់ | ផ្លូវលំជួសជុល | 509 | 93 | 445 | 10.890 | 10.890 | 0% |
| កំពង់ស្វាយ | ត្រពាំងឫស្សី | រំមាំងងាប់ | ផ្លូវលំសង់ថ្មី | 1.103 | 198 | 470 | 19.030 | 19.030 | 60% |
| កំពង់ស្វាយ | នីពេជ | ដូនឈូក | ផ្លូវលំសង់ថ្មី | 1.150 | 204 | 500 | 18.260 | 18.260 | 20% |
| កំពង់ស្វាយ | ក្ដីដូង | ក្ដីដូង | ផ្លូវលំសង់ថ្មី | 735 | 145 | 435 | 13.380 | 13.380 | 45% |
| ប្រាសាទសំបូរ | សំបូរ | សំបូរ | ផ្លូវលំសង់ថ្មី | 816 | 201 | 650 | 12.020 | 12.020 | 20% |
| ស្ទោង | បន្ទាយស្ទោង | បវេង | ទំនប់ស្អាក់ទឹក | 836 | 132 | 480 | 12.580 | 12.580 | 25% |
| ស្ទឹងសែន | ស្រយ៉ូវ | ស្រយ៉ូវត្បូង | ផ្លូវលំសង់ថ្មី | 620 | 164 | 400 | 12.110 | 12.110 | 25% |
| កំពង់ស្វាយ | កំពង់ស្វាយ | ព្រៃព្រះ | ផ្លូវលំជួសជុល | 667 | 209 | 550 | 9.630 | 9.630 | 20% |
| ប្រាសាទសំបូរ | តាំងក្រសៅ | ស្វិយា | ផ្លូវលំជួសជុល | 704 | 51 | 205 | 10.170 | 10.170 | 15% |
| កំពង់ស្វាយ | ជ័យ | ត្រពាំងអារ៉ក្ស ១ | ទំនប់សង់ថ្មី | 929 | 184 | 450 | 16.250 | 16.250 | 60% |
| កំពង់ស្វាយ | ជ័យ | ត្រពាំងអារ៉ក្ស ២ | ទំនប់សង់ថ្មី | 895 | 180 | 415 | 12.330 | 12.330 | 60% |
| កំពង់ស្វាយ | ជ័យ | តាធាវ | ប្រឡាយសង់ថ្មី | 670 | 120 | 270 | 8.820 | 8.820 | 10% |
| ស្ទោង | បន្ទាយស្ទោង | ដូនប៉ុក | ទំនប់ស្អាក់ទឹកថ្មី | 1.674 | 164 | 410 | 24.800 | 24.800 | 15% |
| កំពង់ស្វាយ | ត្បែង | ពោធិ | ផ្លូវលំជួសជុល | 914 | 197 | 750 | 17.470 | 17.470 | 15% |
| កំពង់ស្វាយ | ត្រពាំងឫស្សី | ត្រពាំងថ្ម | ផ្លូវលំសង់ថ្មី | 1.008 | 284 | 600 | 15.150 | 15.150 | 0% |
| 6 | 16 | 28 | | 27.275 | 5,180 | 17,075 | 453.580 | 453.580 | |

**១០.៤-គម្រោងអភិវឌ្ឍន៍ជនបទតាមទំនាបបឹងទន្លេសាប** ( មន្ត្រីចំនួន ០៥ នាក់) (គ្មានសកម្មភាព)

**១០.៥-គម្រោង** ( RIP-III) (មន្ត្រីចំនួន ០៤ នាក់ )

គម្រោង បានអនុវត្តផ្លូវថែទាំខួបចំនួន៥ ខ្សែប្រវែង ៤១,៨៧ គ.ម ក្នុងនោះ÷

- ទួលរកា ដល់ ចើងដើង ប្រវែង ៨,៥ គ.ម ស្រុកបារាយណ៍ សម្រេចបាន ១០០%
- ទំនប់ ដល់ បេង ប្រវែង ៨,២៣ គ.ម ស្រុក ប្រាសាទសំបូរសម្រេចបាន ១០០%
- បេង ដល់ គោល ប្រវែង ៧,៣ គ.ម ស្រុក ប្រាសាទសំបូរម្រេចបាន ១០០%
- ព្រៃក្ដី ដល់ តាំងស្ទោង ប្រវែង ៤,០៨ គ.ម ស្រុក ប្រាសាទសំបូរម្រេចបាន ១០០%
- ថ្មី ដល់ ទឹកអណ្ដូង ប្រវែង ១៣,៧៦ គ.ម ស្រុក ប្រាសាទសំបូរម្រេចបាន ១០០%

**១០.៦-កម្មវិធី ទឹកស្អាត និង អនាម័យ** ( UNICEF) (មន្ត្រីចំនួន ៤ នាក់)

- បានចុះប្រជុំប្រចាំត្រីមាសថ្នាក់ឃុំ ឆ្លុះបញ្ចាំងការអនុវត្តន៍កម្មវិធី CLTS ៤ ឃុំលើ ២០ ភូមិនៅស្រុក ស្ទោង ប្រាសាទសំបូរ សន្ទុក ដោយមានអ្នកចូលរួមសរុប ១២៨ រូប ស្រី ៤៧ រូប
- បានចុះបើកវគ្គបណ្តុះបណ្តាល CLTS ដល់អ្នកសម្របសម្រួលអនាម័យភូមិ ចំនួន ១២ ភូមិថ្មីនៅស្រុក ស្ទោង និងស្រុកសន្ទុក មានអ្នកចូលរួមសរុប ១០៥ រូប ស្រី ៣៥ រូប
- បានរៀបចំប្រជុំប្រចាំត្រីមាសទី ១ ថ្នាក់ខេត្ត ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ សមាសភាពចូលរួមមកពី អង្គការ ជាតិ និងអន្តរជាតិក្នុងខេត្ត អង្គភាពមន្ទីរអប់រំ មន្ត្រីមន្ទីរ សរុប ២៥ រូប ស្រី ១ រូប

**១០.៧-កម្មវិធីកំចាត់មីនខេត្ត** (MAPU ) ( មន្ត្រីចំនួន ០១ នាក់ ) ( គ្មានសកម្មភាព)

**១០.៨-គម្រោង** (LASED) ( មន្ត្រីចំនួន ០២ នាក់ ) ( គ្មានសកម្មភាព)

**១០.៩-គម្រោងស្បៀងបន្ទាន់** (Cash for Work)( មន្ត្រីចំនួន ០៤ នាក់ )

- បានចុះសិក្សាគម្រោងសាច់ប្រាក់ពលកម្ម (EF) ចំនួន ៥ គម្រោងប្រវែង ៣,៣៤៩ គ.ម នៅស្រុក កំពង់ស្វាយ និង ស្រុក សន្ទុក ហើយបានផ្ញើឯកសារទៅក្រសួង អ ជ ប បន្ទាប់មកគម្រោងបានអនុម័យចំនួន ២ ខ្សែ ប្រវែង ១,៥១ គ.ម
- គម្រោងក្រាលក្រួសក្រហមដែលសិក្សាឆ្នាំ ២០១៤ ត្រូវបានអនុម័តចំនួន ២ ខ្សែគឺ ១.ឃុំទីពោ ស្រុក សន្ទុក ប្រវែង ៤,៣៧៧ គ.ម ។ ២.ឃុំ ទ្រៀល ស្រុក បារាយណ៍ ប្រវែង ២,៧ គ.ម

**១០.១០-គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ**( មន្ត្រីចំនួន០៣នាក់ )

នៅភូមិ បញ្ញាជី ឃុំ ត្បូងក្រពើ ស្រុក សន្ទុក មានអតិថិជន ២៦ នាក់ ស្មើ ៥ក្រុម ហើយអតិថិជនម្នាក់ៗខ្ចីប្រាក់ចំនួន ៥០ ម៉ឺនរៀល រយៈពេល ១០ ខែ សរុបទឹកប្រាក់ប្រើដោយអតិថិជនចំនួន ១៣ លានរៀល។ អត្រាការប្រាក់ជាក្រុម ២,២% ទោល ២%។

## III.**ទិសដៅបន្ត**

- សាងសង់ផ្លូវជនបទក្រាលកៅស៊ូ DBST ជំហានទី ២ ប្រមាណជា ១២២,៧ គ.ម ក្នុងនោះគឺ ÷
    - ផ្លូវពីទ្រា ដល់សាគ្រាម ប្រវែង ៤៩ គ.ម ស្រុក ស្ទោង និង ប្រាសាទបល្ល័ង្គ
    - ផ្លូវពីតារាម ដល់ ស្ទោញ ប្រវែង ២០ គ.ម ស្រុកប្រាសាទបល្ល័ង្គ និងស្រុក កំពង់ស្វាយ
    - ផ្លូវពីកំពង់ស្បូវ ដល់ ងន ប្រវែង២០,៤ គ.ម ស្រុកប្រាសាទសំបូរ និងស្រុកសណ្តាន់
    - ផ្លូវពីសាលាវិស័យ ដល់ ក្រយា ប្រវែង ៣២,២ គ.ម ស្រុកប្រាសាទបល្ល័ង្គ
- ថែទាំផ្លូវជាលក្ខណៈខួប ផ្លូវក្រាលគ្រួសក្រហម ចំនួន ០៣ ខ្សែ ប្រវែង ១៥ គ.ម ស្ថិត ក្នុងឃុំត្រពាំងឫស្សី និង ឃុំ ជ័យ ស្រុកកំពង់ស្វាយ និង ឃុំចុងដូង ស្រុកបារាយណ៍ ( គម្រោង TSLRDP)
- អង្គការ ADRA គ្រោង ២០១៥ នឹងផ្តល់បង្គន់អនាម័យចំនួន ២០០ បង្គន់ និង ផ្តល់ធុងចម្រោះទឹកស្អាត ៤៦០ ធុង នៅស្រុក បារាយណ៍ និងសន្ទុក

## IV. **សំណូមពរ**

- រិះរកមធ្យោបាយណាដើម្បីឲ្យសហគមន៍ចូលរួមសាងសង់ និងទិញបង្គន់អនាម័យយកទៅប្រើប្រាស់
- ស្នើសុំថវិកាទៅតាមផែនការសម្រាប់ឆ្នាំ ២០១៥ ឲ្យបានទាន់ពេលវេលា

- គួរមានប្រាក់ឧបត្ថម្ភដល់សមាជិក គ.អ.ភ

ប្រធានមន្ទីរ